UDAYA, Journal of Khmer Studies, 13, 2015

# គំនិតថាប្រទេសខ្មែរចុះស្រុតឱនថយនិងប្រឹងងើបឡើងវិញ នៅសម័យកណ្ដាល[១]

Grégory Mikaelian
*Centre National de la Recherche Scientifique*

## ១. ទស្សនៈចារាំងសេសសម័យអាណានិគម

*ពួកបារាំងសេសសម័យអាណានិគមជាអ្នកដែលបានសិក្សាប្រវត្តិសាស្ត្រខ្មែរមុនគេ ហើយកាលនោះគេតែងយល់ថាសម័យបុរាណជាសម័យល្អប្រសើរខ្ពង់ខ្ពស់។ផ្ទុយទៅវិញគេគិតថាសម័យកណ្ដាលជាសម័យមួយដែលអ្វីៗពុំសូវត្រឹមត្រូវដោយសារគោលធំៗនៃអារ្យធម៌បុរាណរលាយឬស្ទើរសាបសូន្យទៅហើយដូច្នេះប្រវត្តិវិទូមិនចាំបាច់យកមកសិក្សាឡើយ។ គឺប្រព័ន្ធអប់រំនៅទ្វីបអឺរ៉ុបដែលធ្វើឲ្យយល់របៀបនេះ។ កាលនោះអ្នកប្រាជ្ញឲ្យតម្លៃច្រើនទៅលើប្រវត្តិសាស្ត្រសម័យបុរាណ។ សូមបញ្ជាក់ថាន័យនៃពាក្យ "បុរាណ" គឺបារាំងយោងទៅពាក្យ*Antiquité *ហើយច្រើនតែយកអាណាចក្ររ៉ូម៉ាំងមកធ្វើជាគោលដោយចាត់ទុកថាជាអារ្យធម៌ដែលប្រសើរជាងគេ បានសេចក្ដីថាគេចាត់ទុកអាណាចក្ររ៉ូម៉ាំងថាជាគម្រូសម្រាប់អារ្យធម៌ទាំងឡាយក្នុងពិភពលោកទាំងមូល។ សូមរំឭកថាអាណាចក្ររ៉ូម៉ាំងមានជីវិតនិងវិវឌ្ឍន៍ក្នុងរយៈពេលប្រាំសតវត្ស ពោលគឺចាប់ពីឆ្នាំ២៧មុនគ.ស.ដល់ឆ្នាំ៤៧៦ក្រោយគ.ស.។*

*ពេលមកដល់ស្រុកខ្មែរ អ្នកប្រាជ្ញបារាំងជួបប្រទះឃើញអារ្យធម៌អង្គរ ហើយយល់ថាអារ្យធម៌នេះមានលក្ខណៈទូទៅប្រហាក់ប្រហែលគ្នានឹងអារ្យធម៌រ៉ូម៉ាំង។ លក្ខណៈនោះមានបួន ៖ ទីមួយជាអារ្យធម៌ដែលចាស់បុរាណ, ទីពីរមានទឹកដីធំធេងប្រៀបដូចអាណាចក្ររ៉ូម៉ាំង, ទីបីមានប្រាសាទថ្មធំៗ ( ដូចជាអង្គរវត្តនិងបាយ័ន្ត), ទីបួនមានសិលាចារឹកជាច្រើនដែលប្រើភាសាមួយដ៏ខ្ពង់ខ្ពស់ ពោលគឺសំស្ក្រឹត ដែលអាចយកមកប្រៀបធៀបនឹងភាសាឡាតាំងបាន។ គំនិតនេះមានជាទូទៅនៅចន្លោះទសវត្ស១៨៥០និងទសវត្ស១៩៥០ (រូបលេខ១)។*

---

*[១] កំណត់និពន្ធនាយក ៖ នេះពុំមែនជាអត្ថបទក្បោះក្បាយដែលចំណុចលើកឡើងនិមួយៗនៅក្នុងនោះមានភាពល្អិតល្អន់ឡើយ គឺគ្រាន់តែជាការដាក់មកជាសំណេរវិញដោយមានការកែសម្រួលបន្តិចបន្តួចនូវបាឋកថាមួយដែលអ្នកនិពន្ធធ្វើនៅថ្ងៃទី២៥កក្កដា ២០១៤ ជាភាសាខ្មែរ ហើយបន្ទាប់មកជាភាសាបារាំង ក្រោមការចាត់ចែងរួមនៃ យសោធរ និង សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។*

លុះដល់មានគំនិតថាអង្គរជាអាណាចក្ររុងរឿងដូច្នេះហើយ ទើបគេមានគំនិតជាប់ជាមួយនោះថា សម័យក្រោយអង្គរជាសម័យឱនថយនៅក្នុងប្រវត្តិសាស្ត្រខ្មែរ។ យល់យ៉ាងនេះដោយសារតែសម័យក្រោយ អង្គរខ្វះលក្ខណៈទាំងបួននោះឯង គឺថាទីមួយជាអារ្យធម៌ដែលមិនចាស់ប៉ុន្មានទេ រហូតដល់អ្នកប្រាជ្ញបារាំង ប្រើពាក្យថា Moderne ( ទំនើប) ទៀតផង, ទីពីរជានគរតូចមួយដែលបានបាត់បង់ទឹកដីច្រើន, ទីបីសំណង់ ធ្វើអំពីឈើសឹងតែទាំងអស់ ស្ទើរលែងប្រើថ្ម ហើយលែងសាងប្រាសាទធំៗដូចមុនទៀត, ទីបួនមនុស្សនិយម សរសេរចារអ្វីៗទុកលើតែក្រដាសឬស្លឹកច្រើនជាងលើផ្ទាំងថ្ម ពុំតែប៉ុណ្ណោះលែងចារអត្ថបទអ្វីមួយទាំងមូល ជាភាសាសំស្ក្រឹតដូចបុរាណកាលទៀត។

ជាការពិតហើយ ការគិតនិងការជឿតាមគ្នាថាសម័យក្រោយអង្គរជាសម័យឱនថយនោះ មានផល ប្រយោជន៍ចំពោះនយោបាយអាណានិគមបារាំង ដ្បិតគេតែងតែឃោសនាថាគេមកស្រុកខ្មែរដើម្បីជួយស្តារ សង្គ្រោះអារ្យធម៌ខ្មែរដែលស្រុតចុះក្រោយពីសម័យអង្គរមក (រូបលេខ២)។ គេមិនត្រឹមតែឃោសនាទេ គឺគេ ជឿពាក្យខ្លួនឯងនោះទៅទៀត។ គេជឿថាគេមានបេសកកម្មជួយលើកតម្កើងអារ្យធម៌ខ្មែរ ដោយប្រើពាក្យថា Mission civilisatrice មានន័យថាគេត្រូវផ្តល់អារ្យធម៌មួយថ្មីទៅខ្មែរ ព្រោះខ្មែរបាត់បង់អារ្យធម៌ខ្លួនតាំងពី អង្គរធ្លាក់ចុះមក។




រូបលេខ១




រូបលេខ២

ក្រៅពីប្រព័ន្ធអប់រំនៅអឺរ៉ុប ហើយក្រៅពីការជឿខ្លួនឯងថាគេត្រូវផ្តល់អារ្យធម៌ថ្មីទៅខ្មែរ ពួកបារាំងកើតឬបង្កើតគំនិតថាខ្មែរចុះឱនថយនៅសម័យកណ្តាលដោយសារតែស្ថានការទូទៅនៃស្រុកខ្មែរក្នុងស.វ. ទី១៩លំបាកយកភ្នែកមើលខ្លាំងណាស់។ កាលនោះខ្មែរក្រីក្របំផុត ព្រោះតែធ្វើសង្គ្រាមមិនចេះចប់មិនចេះហើយក្នុងរវាងប្រមាណកន្លះសតវត្ស មិនថាជាមួយសៀមឬជាមួយយួនឡើយ។ លុះបារាំងចូលមកឃើញថានៅសម័យបុរាណមានការថ្កុំថ្កើងរុងរឿងគេចៀសពុំផុតទេពីការយល់ថាប្រទេសនេះធ្លាក់ខ្លួនដុនដាបតាំងពីចប់សម័យអង្គរមក។

រឿងទាំងអស់នេះហើយដែលធ្វើឲ្យលោក Bernard Philippe Groslier យល់ថាគឺពួកបារាំងខ្លួនឯងតែម្តងដែលជាអ្នកបង្កើតគំនិតថា ខ្មែរធ្លាក់ខ្លួនស្រុតចុះនៅសម័យកណ្តាល[២]។ គេពុំត្រឹមតែសរសេរអំពីរឿងនេះនៅក្នុងទស្សនាវដ្តីស្រាវជ្រាវដូចជា Bulletin de l'École française d'Extrême-Orient ប៉ុណ្ណោះឡើយ គឺគេបញ្ចូលគំនិតថាឱនថយនេះទៅក្នុងសៀវភៅសិក្សាទៀតផង (រូបលេខ៣)។ សូម្បីតែក្រោយពីបានឯករាជ្យហើយក៏ដោយ ក៏គេនៅតែយល់ជាទូទៅថាគ្មានអ្វីដែលគួរឲ្យចាប់អារម្មណ៍ក្រៅពីអង្គរឡើយរហូតដល់មានពាក្យថាក្រោយពីអង្គរមកគឺជា"សម័យខ្មៅងងឹត"(Cambodia's Dark Age)។ ប៉ុន្តែទោះជាយ៉ាងណាក៏គង់មានអ្នកប្រាជ្ញខ្មែរពីរនាក់ដែលព្យាយាមពន្យល់ថាសម័យកណ្តាលមិនដាច់ ពីសម័យអង្គរទាំងស្រុងទេ។ តាំងពីទសវត្ស១៩៥០មក លោកគ្រូ អូ ឈឿង ហើយបន្ទាប់មកអ្នកគ្រូ ពៅ សាវរស តែងតែបង្ហាញពីភាពល្អប្រសើរនៃវប្បធម៌សម័យកណ្តាល។




រូបលេខ៣

## ២. ទស្សនៈខ្មែរនៅចុងសម័យកណ្តាលស្តីអំពីការចុះស្រុតឱនថយ

ប៉ុន្តែប្រសិនបើយើងយកប្រធានបទនេះមកពិចារណាវែងឆ្ងាយ យើងនៅតែពិបាកអះអាងថាមានតែបារាំងសុទ្ធសាធដែលបង្កើតគំនិតថាខ្មែរធ្លាក់ចុះដុនដាបនៅសម័យកណ្តាល។ តាមពិតទៅគំនិតនេះមានតាំងពីមុនបារាំងចូលមកស្រុកខ្មែរម៉្លេះ គ្រាន់តែថា "ឱនថយ" នេះ ខ្មែរនិងបារាំងឲ្យហេតុមិនដូចគ្នាទេ។

ចាប់តាំងពីចុងស.វ.ទី១៨មក ខ្មែរជាទូទៅយល់ថាស្រុកខ្លួនចុះដុនដាបដោយសារតែបាត់ព្រះគោ។ ទោះជាប្រភពណាក៏ដោយមិនថាព្រះរាជពង្សាវតារ,ពុទ្ធទំនាយ,ឬការនិយាយពីមាត់មួយទៅមាត់មួយឡើយ

[២] Grolier 1985-1986: 5-30។




រូបលេខ២

ដ្បិតសាច់រឿងមានតែមួយ។ បើសង្ខេបតែមួយម៉ាត់មកគឺថា តាំងពីបន្ទាយលង្វែករលំ ហើយបាត់ព្រះគោដែលមានក្បួននៅក្នុងពោះនោះ ខ្មែរដែលធ្លាប់កប់ពពកក្លាយធ្លាក់ខ្លួនមកជ្រកអាចម៍ជន្ទេន។ សៀមឈ្នះពានក៏មាន, យួនឈ្នះពានក៏មាន, ច្បាំងគ្នាឯងក៏មាន។ ក្នុងន័យនេះ សម័យលង្វែកមុនពេលបែកបន្ទាយនោះជាសម័យដ៏ល្អប្រសើរ។ សូម្បីតែសព្វថ្ងៃនេះហើយក៏ដោយ ក៏នៅមានគេជឿរឿងព្រះគោព្រះកែវរហូតដល់មានបោះពុម្ពជាសៀវភៅទៀតផង(រូបលេខ២)។

ប្រការដែលខ្មែរនិងបារាំងបកស្រាយខុសគ្នាអំពីរឿងចុះស្រុតតែមួយនេះទាក់ទងទៅនឹងការយល់អំពីពេល។ បារាំងយល់ថាពេលជាខ្សែបន្ទាត់ ឬក៏ថាជាកាំជណ្ដើរដែលមនុស្សឡើងពីក្រោមទៅលើ។ក្នុងន័យនេះកាំខាងលើតែងតែល្អជាងកាំដែលនៅក្រោម មានន័យថាអនាគត តែងតែល្អប្រសើរជាអតីតកាល។ បើមើលទៅបច្ចេកទេសឃើញថាគួរឲ្យគិតដូច្នេះមែន ដោយសារការលូតលាស់តែងទៅមុខមិនដែលចប់ (Progrès)។ ស្រុកណាមិនស្គាល់បច្ចេកទេសទំនើបដូចជាស្រុកខ្មែរ ពួកអឺរ៉ុបយល់ថាគេត្រូវផ្ដល់អារ្យធម៌ថ្មីឲ្យ ហើយអារ្យធម៌នោះមានន័យដូចបច្ចេកទេសទំនើបនោះឯង។ចំពោះខ្មែរវិញពេលជាកង់មួយដែលវិលពុំឈប់,ជាវដ្តដែលចប់មួយហើយមួយថ្មីផ្ដើមឡើងទៀត,ជាកល្បដែលតពីមួយទៅមួយ។ បើនិយាយក្នុងព្រះពុទ្ធសាសនា គេជឿថាសាសនាព្រះសមណគោតមមាន៥០០០ឆ្នាំក្រោយពីព្រះអង្គចូលនិព្វានទៅ។ បច្ចុប្បន្ននេះជាពេលដែលសាសនាទ្រុតទ្រោមខ្លាំងទៅៗ រីឯការបាក់បែកខ្ចាត់ខ្ចាយបន្ទាយលង្វែកជាសញ្ញាឲ្យដឹងថាមនុស្សលោកចូលមកក្នុងសម័យកលិយុគហើយ រហូតដល់គេប្រើពាក្យថា "លង្វែកសាសនា" គឺថាជាពេលច្របូកច្របល់វឹងវ៉ឹងដែលស្ថិតនៅចន្លោះកល្បពីរ។

រឿងនិទានទាំងប៉ុន្មានស្ដីពីការបាក់បែកបន្ទាយលង្វែកតែងតែទាក់ទងទៅនឹងហេតុការណ៍ប្រវត្តិសាស្ត្រអំពីចម្បាំងនៅចុងស.វ.ទី១៨ ដែលសៀមជាអ្នកវាយលុក[៣]។ ព្រឹត្តិការណ៍នោះកើតឡើងនៅគ.ស.១៧៧៨ កាលដែលសន្តតិវង្សសៀម "ចក្រី" វាយនគរវៀងចន្ទន៍ហើយយកប្រតិមាព្រះកែវមរកតមកទុកនៅក្រុងទេព (បាងកក) ដែលគេប្រតិស្ឋានជាឱឡារិកនៅឆ្នាំ១៧៨៥ថាជាព្រះពុទ្ធរូបដែលថែរក្សាព្រះញាតិវង្សសៀម[៤]

[៣] Ang 1997: 62-69 និង Chandler 2008: 101។

[៤] Woodward 1997: 506 និង Lingat 1935: 8-38។

(រូបលេខ២៥)។ នេះជាព្រឹត្តិការណ៍ធំធេងពន់ប្រមាណនៅឥណ្ឌូចិនជាន់នោះរហូតដល់ខ្មែរយករឿងព្រះកែវមកផ្សំជាមួយនឹងរឿងបាក់បែកបន្ទាយលង្វែកហើយចារក្នុងព្រះរាជពង្សាវតារទៀតផង។ ឃើញថាគេបញ្ចូលរឿងនេះមកក្នុងបរិបទព្រះពុទ្ធសាសនាពេញទី។ម្យ៉ាងទៀតរំឭកពីការបាក់បែកបន្ទាយលង្វែកជាមធ្យោបាយមួយសម្រាប់ថ្កោលទោសការឈ្លានពានពីសំណាក់សត្រូវទាំងឡាយ ជាពិសេសសៀមដែលជាសត្រូវធំជាងគេនៃខ្មែរនៅដើមស.វ.ទី១៩ (រាជ្យព្រះបាទអង្គច័ន្ទទី៣ ៖ គ.ស.១៨០៦ - ១៨៣៥)។ តាមពិតទៅ នៅមុនស.វ.ទី១៨ យើងមិនឃើញមានស្លាកស្នាមអ្វីប្រាកដដែលបង្ហាញថាខ្មែរសោកស្ដាយខ្លាំងពីការបាក់បែកខ្ចាត់ខ្ចាយបន្ទាយលង្វែកនោះទេ។




រូបលេខ២៥

# ៣. ការប្រឹងងើបឡើងវិញនៅសម័យកណ្ដាល

ប្រការដែលពុំសូវមានការសោកស្ដាយពីការបាក់បែកបន្ទាយលង្វែក គឺទីមួយមកពីរាជ្យអំណាចខ្មែរកាលនោះនៅរឹងមាំ។ ព្រះរាជាខ្មែរបង្កើតរាជធានីឧត្តុង្គតមកទៀតនៅដើមស.វ.ទី១៧ ហើយរាជ្យអំណាចពេលនោះនៅមានពេញលេញ។ ការជួញដូរជាមួយប្រទេសជិតឆ្ងាយធ្វើឡើងជាធម្មតា ហើយគួរឲ្យចាប់

*អារម្មណ៍ថាខ្មែរមានលទ្ធភាពទិញអាវុធទំនើបដើម្បីទប់ទល់នឹងសៀម, ចងសម្ព័ន្ធមិត្តជាយុទ្ធសាស្ត្រជាមួយស្តេចយួនត្រកូល* Nguyên, *ឆ្លើយឆ្លងគ្នាជាមួយមណ្ឌលអំណាចឆ្ងាយៗដូចជា* Goa, *ជប៉ុនៗលៗ ទាំងនេះបង្ហាញថាគ្មានមូលហេតុដែលធ្វើឲ្យមានការសោកស្តាយខ្លាំងពីបន្ទាយលង្វែករលំនោះទេ។ប្រការទីពីរព្រះរាជាដែលគង់នៅឧត្តុង្គហាក់ដូចជាគ្រាន់តែយល់ថាព្រះអង្គគ្រងរាជ្យបន្តមកពីលង្វែកជាធម្មតាតែប៉ុណ្ណោះ ដ្បិតគ្រប់អង្គទាំងមុនទាំងក្រោយនៅក្នុងសន្តតិវង្សតែមួយ។ ម្យ៉ាងវិញទៀតអតីតព្រះរាជវាំងឧត្តុង្គនិងវត្តត្រឡែងកែងនៅលង្វែកស្ថិតនៅឆ្ងាយពីគ្នាប្រមាណតែ៦គ.ម.ប៉ុណ្ណោះ បើទាញខ្សែបន្ទាត់ឲ្យត្រង់ពីមួយទៅមួយ។ រីឯរាជប្រវេណីដែលមានមកនៅលង្វែកត្រូវតែរក្សាគោរពតមកទៀតនៅឧត្តុង្គជាធម្មតា មិនត្រូវឲ្យមានការបាត់បង់ឬប្រាសចាកអ្វីទាំងអស់។*

*បើនិយាយពីទិន្នន័យដែលបានត្រង់មកពីស.វ.ទី១៧ គឺមានដោយកម្រ ឬក៏ថាមានមិនច្រើនទេ។ ប្រពៃណីដែលយើងអាចរកបានឃើញ មិនពិសេសអ្វីតែនឹងលង្វែកប៉ុណ្ណោះឡើយ តែគឺអាចនិយាយបានសម្រាប់សម័យកណ្តាលទាំងមូល បានសេចក្តីថាតែងមានតាំងពីសម័យអង្គរមក ដ្បិតគេច្រើនតែផ្អែកលើគំនិតអំពី "មហានគរ" (អង្គរធំ) ដែលមានប្រាសាទបាយ័ន្តនៅចំកណ្តាល។ ឧទាហរណ៍ ទីបូជាធំនៅលង្វែកគឺវត្តត្រឡែងកែង។ ឈ្មោះវត្តនេះគេដាក់ឡើងតាមរូបរាងដំបូលប្រភេទ "មុខដាច់" ពោលគឺដែលមានហោជាងលយចេញមកទិសទាំងបួន ហើយដែលចំពីក្រោមនោះគេតម្កល់ព្រះពុទ្ធរូបបួនអង្គឈរបែរមកទិសទាំងបួនដូចគ្នា។ ប្រពៃណីមុខបួនឬចតុមុខ*[៥] *ច្បាស់ជាមុខបួននៅប្រាសាទបាយ័ន្តនោះឯងដែលជាប្រភព ហើយដែលយកមកសម្របនឹងព្រះពុទ្ធសាសនាសម័យកណ្តាលដែលផ្អែកខ្លាំងលើព្រះស្រីអារ្យមេត្រីយ៍ ព្រោះគេជឿថាព្រះអង្គទាំងបួននោះក៏ជានិមិត្តរូបនៃព្រះទីប្រាំដែលនឹងចុះមកប្រោសមនុស្សនៅអនាគតដែរ*[៦]*។*

*ពិនិត្យតែសិលាចារឹកទៅឃើញថានៅស.វ.ទី១៦និងទី១៧ ស្តេចខ្មែរធ្វើអ្វីៗតែងតែយោងទៅអង្គរ។ គេយកឈ្មោះរាជធានីអង្គរ ពោលគឺ "ស្រីយសោធរ" មកដាក់ឈ្មោះរាជធានីក្រោយមក ហើយដែលក្លាយជា "ស្រីសន្ធរ"។ បើនិយាយតែរឿងឈ្មោះដដែល នៅមានឧទាហរណ៍ផ្សេងៗទៀត ដូចជា "សូរ្យវម៌" នៅសម័យអង្គរក្លាយមកជា "សូរិយោពម៌" នៅសម័យកណ្តាល*[៧]*។ ពុំតែប៉ុណ្ណោះ ប្រភពនៅសម័យកណ្តាលច្រើននិយាយថា ស្តេចជា "កំពូលឥន្ទ្រប្រស្ថនគរ" ហើយយើងដឹងថា ឥន្ទ្រប្រស្ថ (បាលីថា ឥន្ទបត្ត) នេះជាឈ្មោះក្រុងដែលព្រះឥន្ទ្រគង់នៅ រីឯវាំងនៃព្រះឥន្ទ្រមានឈ្មោះជាបាលីថា "ពេជយន្ត"*[៨] *សឲ្យឃើញថាអ្វីៗក៏យោងទៅមហានគរនោះឯង។*

*ទោះបីក្រោមផ្ទៃដ្ឋានវាំងក៏មនុស្សម្នាទូទៅតែងតែយោងលើមរតកអង្គរជាធំ ហើយមរតកនេះជាខ្លឹមសារនៃប្រពន្ធ័អប់រំ ដូចអ្នកគ្រូ ពៅ សាវរស ធ្លាប់បង្ហាញនៅតាមសំណេរផ្សេងៗជាច្រើន។ អ្វីៗដែលជា*

---

[៥] *អាំង ជូលាន ២០១៤: ៨៣-៨៩។*

[៦] Thompson 1995: 153-166។

[៧] *សំស្ក្រឹត "សូរ្យ" បើជាបាលីគឺ "សូរិយ"។*

[៨] *អានមួយម៉ាត់ៗគឺ* /pic yəɔn/ *បើអានញាប់តាមមាត់និយាយគឺ* /pəyəɔn/ *លុះបកមកសរសេរវិញក្លាយទៅជា "បាយ័ន្ត"។*

មរតកអង្គរ គេហៅថា "ត្រៃភេទ"[៩] នៅសម័យកណ្ដាល។ ដើមឡើយត្រៃភេទប្រែថា "វេទទាំងបី" (វិជ្ជាទាំងបី) រាយមកគឺ ឬគ្វេទ, សាមវេទ, យជុវេទ។ តែការយល់ជាទូទៅច្រើនសម្ដៅទៅន័យពីរយ៉ាង ៖ ម្យ៉ាងសម្ដៅលើសត្រា ឬក៏វិជ្ជាណាដែលមានលក្ខណៈជាព្រហ្មញ្ញសាសនា ឯម្យ៉ាងទៀតគឺជាឈ្មោះសត្រាដែលមានចំណងជើងថា "ត្រៃភេទត្រៃតយុគ" ដែលរៀបរាប់ពីកំណើតលោកតាំងពីក្រិតយុគ (យុគមុនគេបង្អស់) តមកដល់ត្រៃតយុគ (យុគជាទី២បន្ទាប់មក) ឈានចូលមកដល់យុគទី៣ដែលហៅថាទ្វាបរយុគ។ នៅសម័យកណ្ដាលនរណាដែលចង់ចូលបម្រើហ្លួងក្នុងរាជការត្រូវតែចេះត្រៃភេទជាចាំបាច់។ មរតកព្រហ្មញ្ញសាសនាទាំងអស់នេះជាខ្លឹមសារនៃប្រព័ន្ធអប់រំនាសម័យកណ្ដាល។

ម្យ៉ាងវិញទៀត ចំពោះកវីបណ្ឌិតនៅសម័យកណ្ដាល ត្រៃភេទនេះត្រូវមានទំនាក់ទំនងច្បាស់នឹងប្រាសាទអង្គរវត្ត។ ក្រោយពីយុគទាំងពីរដំបូង (ក្រិតតយុគ និងត្រៃតយុគ) មនុស្សឈានចូលក្នុងយុគទី៣ហៅថាទ្វាបរយុគ។ គឺនៅពេលនោះហើយដែលសាសនាព្រះពុទ្ធចាប់ផ្ដើមលូតលាស់។ ក្នុងរឿងរាមកេរ្តិ៍ តួអង្គទាំងប៉ុន្មានសុទ្ធសឹងកើតឡើងក្នុងយុគនោះ។ ព្រះរាមដែលជាអ្នកកាន់ព្រះពុទ្ធសាសនាទៅវាយបង្ក្រាបនគរលង្កា ដែលគ្រប់គ្រងដោយក្រុងរាពណ៍ជាអ្នកកាន់ព្រហ្មញ្ញសាសនា។ ក្នុងសំណេររាមកេរ្តិ៍នៅស.វ.ទី១៧ គេរៀបរាប់ពីនគរលង្កាហាក់ដូចជារៀបរាប់ពីរាជធានីអង្គរតែម្ដង។ គម្រូមានតែមួយ ឯអ្នកសាងក៏មានតែម្នាក់ ពោលគឺព្រះពិស្ណុការ បានសេចក្ដីថាចំពោះគេ លង្កាជានិម្មិតរូបអង្គរដែលជាទីក្រុងបុរាណហើយដែលកាន់ព្រហ្មញ្ញសាសនា[១០]។

ផុតពីយុគទី៣ទៅ យុគទី៤ជាយុគចុងក្រោយ ហៅថា កលិយុគ។ ខ្មែរជឿថាខ្លួនរស់នៅក្នុងកលិយុគនោះឯង។ ក្នុងកលិយុគនេះហើយដែលសាសនាព្រះសមណគោត្តមនឹងត្រូវរលាយ ទាល់តែក្រោយមកទៀតទើបព្រះស្រីអារ្យមេត្រីយ៍យាងចុះមកប្រោស។ ស្ដេចខ្មែរនៅសម័យកណ្ដាលមានករណីយកិច្ចកែរទម្រង់នគរខ្មែរតាមគន្លងធម៌ព្រះពុទ្ធ ដើម្បីបានទាន់ព្រះស្រីអារ្យ។ ដើម្បីទៅដល់គោលដៅនេះ ស្ដេចតែងតែយោងទៅលើបុព្វកាលនឹងប្រពៃណីសម័យអង្គរ គឺហាក់ដូចជាត្រឡប់មកទ្វាបរយុគសម័យព្រះរាមវាយក្រុងលង្កា ឬក៏អាចនិយាយថាសម័យដែលព្រះពុទ្ធសាសនាមានជោគជ័យលើព្រហ្មញ្ញសាសនា។ ហេតុនេះហើយបានជាស្ដេចខ្មែរតែងតែយកព្រះរាមជាគម្រូ។ សរុបសេចក្ដីទៅ ដោយសារព្រះអង្គយល់ថារស់ក្នុងសម័យកលិយុគ ដែលជាសម័យចុះស្រុតឱនថយ ព្រះអង្គក៏ខំប្រឹងងើបឡើងវិញដោយលើកយកបុរាណកាលធ្វើជាគម្រូ។ ឧទាហរណ៍មានច្រើន តែនៅទីនេះយកតែមួយចំនួនតូចមកនិយាយក៏ល្មមគ្រប់គ្រាន់ដែរ ៖

- នៅស.វ.ទី១៦ មានព្រះរាជាដ៏ឆើតមួយអង្គព្រះនាមអង្គច័ន្ទ ឬហៅថាច័ន្ទរាជា (ប្រ. គ.ស.១៥២៨ - ១៥៦៦) ដែលកសាងឬស្ដារអ្វីៗដោយយកមរតកចាស់នៃដូនតាមកធ្វើជាគម្រូ។ ឧទាហរណ៍ស្ដែងមួយគឺព្រះអង្គឲ្យគេឆ្លាក់បំពេញផ្ទាំងជញ្ជាំងរបៀងអង្គរវត្តនៅជ្រុងឦសានដែលកាលនោះនៅទំនេរតែងងពុំទាន់

[៩] Pou 2011: 6-7និង Mikaelian 2012: 285។

[១០] Mikaelian 2008: 51-71។

មានចម្ងាក់។ សាច់រឿងចម្លាក់បន្ថែមនោះស្រង់ចេញពីរឿងក្នុងសាសនាព្រាហ្មណ៍និកាយព្រះនារាយណ៍ ហើយបើពិនិត្យមើលសិលាចារឹកដែលនិយាយពីការឲ្យឆ្លាក់នេះ យើងឃើញថាព្រះអង្គច័ន្ទបញ្ជាឲ្យគេឆ្លាក់ "រូវេង" (ប្រែថា "ដូចព្រេងនាយ, ដូចបុរាណកាល")[១១]។

- ដោយសារធ្លាប់ផ្អែកមូលដ្ឋានលើប្រពៃណីអង្គរបានបីសតវត្សមកដូច្នេះហើយ ទើបបានជានៅស.វ.ទី១៧ព្រះរាជាហ៊ានកែទម្រង់នគរតាមវិធីបរទេស។ "ព្រះរាមចូលសាសន៍" ប្រើវិធីជ្វាដើម្បីកែទម្រង់សេដ្ឋកិច្ចនៅពាក់កណ្ដាលស.វ.ទី១៧[១២]។ លុះមកដល់ចុងសតវត្សដដែលនោះ ព្រះបាទជ័យជេដ្ឋាទី៣ងាកទៅប្រើវិធីសៀមវិញ[១៣]។
- នៅស.វ.ទី១៩ព្រះបាទអង្គឌួង (ប្រ. គ.ស.១៨៤៦-១៨៦០) ជាអ្នកចាប់ផ្ដើមគោរពបូជាព្រះគោដែលធ្លាប់ល្បីល្បាញខ្លាំងក្នុងព្រហ្មញ្ញសាសនាដោយភ្ជាប់មកនឹងព្រះកែវ (១៨៥១)[14]។ ម្យ៉ាងទៀតក្នុងរាជ្យនេះមានការកែទម្រង់ច្រើនវិស័យទៀត។ បើនិយាយពីសេដ្ឋកិច្ច គេអាចលើកឧទាហរណ៍ផ្លូវពីឧត្ដុង្គទៅកំពត, ខាងសាសនាមានការបង្កើតនិកាយធម្មយុត្ត, ខាងច្បាប់មានការរៀបចំក្រិតក្រមសាជាថ្មីច្រើន, បើខាងអក្សរសិល្ប៍វិញគឺមានការប្រែជាតកពីភាសាសៀម[១៥]។

បើនិយាយសង្ខេបមក គំនិតថាស្រុកខ្មែរចុះស្រុតឱនថយមានបីយ៉ាង ក្នុងបីដំណាក់កាលដែលជាន់គ្នាខ្លះៗ ៖

- នៅស.វ.ទី១៦និងទី១៧ ព្រះរាជាតែងតែលើកប្រពៃណីអង្គរមកធ្វើជាគោលឬជាគ្រឹះនៃការប្រឹងងើបឡើងវិញក្នុងបរិបទ "លង្វែកសាសនា" មានន័យថាចុះស្រុតនោះមកពីឃ្លាតឆ្ងាយពីប្រពៃណីអង្គរ។
- នៅស.វ.ទី១៨និងទី១៩ មានកើតជំនឿលើសពីនោះទៅទៀត គឺថាការបាក់បែកលង្វែកជានិម្មិតរូបនៃការបាត់បង់ប្រពៃណីអង្គរ។ ដូច្នេះបាក់បែកលង្វែកមានន័យថាជាពេលដែលប្រទេសចាប់ផ្ដើមចុះស្រុតឱនថយ។
- លុះមកដល់សម័យអាណានិគមបារាំងគេបែរទៅគំនិតដើមថា ការចុះស្រុតនោះកើតឡើងមកពីឃ្លាតឆ្ងាយប្រពៃណីអង្គរ។ ដែលខុសពីមុននោះគឺនៅត្រង់ថាព្រះរាជាលែងមានអំណាចដូចមុនទៀត ដូច្នេះហើយលែងមានសកម្មភាពអ្វីក្នុងការកែទម្រង់ប្រទេស។ នៅជំនាន់នោះ បារាំងយកវិធីទំនើបមកកែប្រែស្រុក ហើយច្រើនតែធ្វើឲ្យបាត់បង់ប្រពៃណីបុរាណជាពិសេសប្រពៃណីក្សត្រ។

---

[១១] អាំង ជូលាន ២០០៧-២០០៨: ៧៥-៧៧ និង ២០០៨-២០០៩: ៧៩-៨០។

[១២] Kerstern 2006: 1-22។

[១៣] Mikaelian 2009។

[១៤] Baptiste et Zephyr 2008: 50-51។

[១៥] Népote 2000: 124-134។

*ប្រការនេះឯងដែលធ្វើឲ្យនាម៉ឺនខ្មែរជាច្រើនយល់ថាចុះស្រុតនេះដោយសារពួក "អសុរា" ចូលស្រុក (កាលនោះគេខ្សឹបខ្សៀវគ្នាហៅពួកបារាំងថា "អសុរាដៃដែកភ្នែកប្រាក់")*[១៦]។

# ឯកសារយោង

*អាំង ជូលាន, “ខ្មែរប្រឹងងើបឡើងវិញនៅស.វ.ទី១៦”*, *KhmeRenaissance* 2, ២០០៦-២០០៧: ១០៥-១០៨។

__________, *“ដូចបុរាណកាល!”*, *KhmeRenaissance* 3, ២០០៧-២០០៨: ៧៥-៧៧។

__________, *“អតីត - បច្ចុប្បន្ន - អនាគត”*, *KhmeRenaissance* 4, ២០០៨-២០០៩: ៧៩-៨០។

__________, *“បតុមុខ”*, *KhmeRenaissance* 9, ២០១៣-២០១៤: ៨៣-៨៩។

Ang, Chouléan. “Nandin et ses avatars”, In. H. Jessup et T. Zéphir (éd.). *Angkor et dix siècles d’art khmer*. Réunion des Musées Nationaux. Paris. 1997: 62-69.

Au, Chhieng. *Fondements du deuxième traité de protectorat sur le Cambodge*. Domat-Moncherstien. Paris. 1941.

Baptiste, Pierre & Zephyr, Thierry. *L’Art khmer dans les collections du Musée Guimet*. Réunion des Musées Nationaux. Paris. 2008.

Chandler, David. *A History of Cambodia*. Fourth Edition. Westview Press. 2008.

Groslier, Bernard Philippe. “L’image d’Angkor dans la conscience khmère.” *Seksa Khmer* 8-9. 1985-1986: 5-30.

Kersten, Carool. “Cambodia’s Muslim King: Khmer and Dutch Sources on the Conversion of Reameathipadei I, 1642-1658.” *Journal of Southeast Asian Studies* 37. 2006: 1-22.

Lingat, Robert. “Le culte du Bouddha d’Emeraude.” *Journal of the Siam Society* XXVII. 1935: 8-38.

Mikaelian, Grégory. “La *Gloire* du *Prince charmant*. De la reconfiguration des pratiques discursives du pouvoir dans le royaume khmer du XVII^e siècle.” *Péninsule* 56, *Hommage à Jacques Népote (II)*,. 2008: 51-70.

______. *La royauté d’Oudong. Réformes institutionnelles et crise du pouvoir dans le royaume khmer du XVII^e siècle*. PUPS. Paris. 2009.

______. “Des sources lacunaires de l’histoire à l’histoire complexifiée des sources. Eléments pour une histoire des renaissances khmères (*c*. XIV^e-*c*. XVIII^e siècles).” *Péninsule* 65. 2012: 259-304.

______. “L’arrivée des démons aux mains de fer”, In. Christophe Bertrand, Caroline Herbelin, Jean-François Klein (éd.). *Indochine. Des territoires et des hommes. 1856-1956*. Gallimard- Musée de l’Armée. Paris. 2013.

[១៦] Au 1941 និង Mikaelian 2013: 50-51។

Népote, Jacques. "Le Cambodge (1782-1866) et les Britanniques." *Péninsule* 41. 2000: 107-137.

Pou, Saveros. "L'épigraphie post-angkorienne", transcription d'une communication inédite à la Société Asiatique prononcée le 28 avril 2011. Paris. 2011: 6-7.

Thompson, Ashley. *Mémoires du Cambodge*. Université de Paris-VIII. 1999: 153-166.

Woodward, Hiram, "The Emerald and Sihing Buddhas: interpretations of their significance." In. *Living a Life in Accord with Dhamma*. Silpakorn University. Bangkok. 1997: 502-513.

## សង្ខេប

## គំនិតជាប្រទេសខ្មែរចុះស្រុតឱនថយនិងប្រឹងងើបឡើងវិញនៅសម័យកណ្ដាល

Grégory Mikaelian

*គំនិតដែលថាកម្ពុជាធ្លាក់ចុះស្រុតតាំងពីផុតសម័យអង្គរមកទល់សព្វថ្ងៃនេះមានមកតាំងពីមុនជំនាន់អាណានិគមន៍ម្ល៉េះ គឺថាមិនដូចអ្នកខ្លះស្មានឬអះអាងនោះទេ។ ចាប់តាំងពីដើមសម័យកណ្ដាលមក ខ្មែរយល់ថាខ្លួនរស់នៅក្នុងយុគខ្មៅងងឹតរីងស៊ីងមួយដែលព្រះរាជានានាត្រូវធ្វើឱ្យប្រសើរឡើងវិញដើម្បីពេលណាមួយឈានទៅដល់យុគភ្លឺស្វាង។ ការកែទម្រង់ទាំងអម្បាលម៉ានធ្វើឡើងដោយយកសម័យអង្គរដ៏រុងរឿងនិងគន្លងដែលបុព្វការីដើរពីជំនាន់នោះមកជាគម្រូ ពោលគឺថាប្រពៃណីបុរាណជាផ្លូវសម្រាប់រកច្រកចេញផុតពីទុក្ខសោកនាបច្ចុប្បន្ន ហើយនាំទៅរកក្ដីសុខនៅអនាគតផង។ ការយល់ឃើញពីយុគងងឹតនោះមានច្រើនបែបផែន ប៉ុន្តែទាំងអស់នោះសុទ្ធសឹងជម្រុញឱ្យមានសន្ទុះចិត្តលើកស្ដានភាពវប្បធម៌និងនយោបាយឱ្យខ្ពស់ថ្កុំថ្កើងឡើងវិញច្រើនលើកច្រើនសាចាប់តាំងពីស.វ.ទី១៨មក។*

## RÉSUMÉ

*L'idée de déclin et de renaissance du Cambodge à l'Epoque moyenne*

Grégory Mikaelian

Contrairement aux apparences, l'idée que le Cambodge est entré dans une période de déclin depuis la fin de l'époque angkorienne et jusqu'à l'époque contemporaine trouve sa source en amont de la

période coloniale. Dès le début de la période moyenne, les Cambodgiens pensent vivre un âge du chaos dans lequel les rois ont pour mission de réformer le royaume dans l'attente d'un nouvel âge d'or. Ces réformes ont pour inspiration les temps glorieux d'Angkor et la haute culture des Anciens, la Tradition servant alors de recours au désarois du présent, contre l'inquiétude que procure l'avenir. Variable dans ses formes, cette croyance décliniste fut le moteur d'une renaissance culturelle et politique, à plusieurs reprises depuis le XIVe siècle.

## ABSTRACT

*The idea of decline and of attempts at renaissance of Middle Period Cambodia*

Grégory Mikaelian

Contrary to appearances, the idea that Cambodia entered a period of decline from the end of the Angkorian to the Modern period finds its origins before the colonial era itself. From the beginnings of the Middle Period, Cambodians considered themselves to be living in an age of chaos, in which kings were to reform the kingdom while awaiting a new golden age. These reforms were inspired by the glorious era of Angkor and the high culture of the Ancients, Tradition serving as a recourse against the disarray of the present, staving off concerns harboured by the future. This belief in decline was varied in form and served as the driver of a cultural and political renaissance at mutiple junctures from the fourteenth century on.